សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)
Cambodian Water Supply Association (C.W.A)

# សេចក្តីជូនដំណឹង
# ស្តីពី
# ការដេញថ្លៃផ្គត់ផ្គង់បំពង់ទឹកស្អាត ជាមួយ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) អង្គការយូនីសេហ្វ (UNICEF) និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសេកគង់ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតក្រាំងចេក ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតវាលពង់ ស្ថិតនៅក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតវិនគារ ស្ថិតនៅក្នុងស្រុកបូរីជលសារ ខេត្តតាកែវ បាននឹងកំពុងអនុវត្តគម្រោង «**បង្កើននូវភាពធនសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនរស់នៅក្នុងតំបន់ដែលបានរងគ្រោះពីគ្រោះធម្មជាតិ ដែលមិនទាន់មានបណ្តាញទឹកស្អាត**» ក្រោមជំនួយថវិកាពីអង្គការយូនីសេហ្វ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ សមាគមមានកិត្តិយសសូមអញ្ជើញក្រុមហ៊ុនផ្គត់ផ្គង់សម្ភារៈបំពង់ទឹកស្អាតក្នុងព្រះរាជាណាចក្រកម្ពុជា ចូលរួមដេញថ្លៃផ្គត់ផ្គង់បំពង់ទឹកស្អាតជូនប្រតិបត្តិករទឹកស្អាតទាំងបួនខាងលើ ដូចមាន លក្ខខណ្ឌលម្អិតដូចខាងក្រោម៖

1. គម្រោងត្រូវការបំពង់នាំទឹកស្អាតប្រភេទ HDPE ដែលមានលក្ខណៈដូចក្នុងតារាងខាងក្រោម៖

| ប្រភេទ និងលក្ខណៈបំពង់ទឹកស្អាត | ប្រវែង (ម៉ែត្រ) |
|---|---|
| HDPE PE100 PN8 dia 110mm | 6,156 |
| HDPE PE100 PN8 dia 90mm | 13,450 |
| HDPE PE100 PN10 dia 75mm | 1,050 |
| HDPE PE100 PN10 dia 63mm | 37,350 |

2. រាល់ឯកសារដេញថ្លៃរួមមាន៖ ពាក្យសុំដេញថ្លៃ និងឯកសារភ្ជាប់នានា ត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត រួចផ្ញើមកការិយាល័យសមាគម រៀងរាល់ម៉ោងធ្វើការឲ្យបានមុនថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១។ រាល់ឯកសារដេញថ្លៃទាំងឡាយដែលបានដាក់ក្រោយកាលបរិច្ឆេទ មិនត្រូវបានពិចារណាឡើយ។
3. ក្រុមហ៊ុនដែលទទួលបានជោគជ័យ ត្រូវដឹកជញ្ជូនបំពង់ទឹកស្អាត ទៅកាន់ស្ថានីយទាំងបួនខាងលើ យ៉ាងយូរបំផុតត្រឹម**ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២**។ ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ អាចមកទទួលឯកសារដេញថ្លៃនៅសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ដោយឥតគិតថ្លៃ ដែលមានអាសយដ្ឋានដូចរៀបរាប់ខាងក្រោម ឬទាញយកពីគេហទំព័រ www.cwa.org.kh ឬទំព័រហ្វេសប៊ុក Cambodian Water Supply Association និង អ៊ីមែល៖ info@cwa.org.kh។ ***រាល់តម្លៃត្រូវបូកបញ្ចូលពន្ធលើតម្លៃបន្ថែម (VAT) ឬបញ្ជាក់ពីការបង់ពន្ធកាត់ទុក (Withholding Tax) ក្នុងករណីពុំមាន (VAT)។***
4. ការបើកស្រោមសំបុត្រដេញថ្លៃនឹងត្រូវប្រព្រឹត្តឡើងជាសាធារណៈនៅការិយាល័យសមាគម នា**ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ២:០០រសៀល** ដែលមានអ្នកចូលរួមមកពីតំណាងស្ថានីយផ្គត់ផ្គង់ទឹកស្អាត តំណាងអង្គការយូនីសេហ្វ តំណាងមកពីក្រសួងឧសហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងតំណាងក្រុមហ៊ុនដាក់ដេញថ្លៃ។
5. **អាសយដ្ឋានទំនាក់ទំនង និងដាក់ពាក្យ៖** មជ្ឈមណ្ឌលភ្នំពេញ អគារF ជាន់ទី២ វិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញឬ ទូរស័ព្ទលេខ៖ ០១២ ៤៩៤ ៧៦០ ឬ ០១៧ ៧៩៩ ៣៣៧ ឬ ០៧០ ៧៩៩ ៣៣៧ ឬ ០៩៧៧ ១៧៩ ៩៤៣។ អ៊ីមែល៖ info@cwa.org.kh គេហទំព័រ៖ www.cwa.org.kh